ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*ថ្ងៃ ពុធ ៦ កើត ខែ ផល្គុន ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤*
*រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០២១*

# សេចក្តីប្រកាសព័ត៌មាន
# កិច្ចប្រជុំគណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុករៀបចំ សេចក្តីព្រាងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចឌីជីថល និង សេចក្តីព្រាងក្របខណ្ឌគោលនយោបាយរដ្ឋាភិបាលឌីជីថល
# ស្តីពី
# "សេចក្តីព្រាងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥"

នាព្រឹកថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០២១ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងជាប្រធានគណៈកម្មាធិការអន្តរក្រសួងទទួលបន្ទុករៀបចំសេចក្តីព្រាងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចឌីជីថល និងសេចក្តី ព្រាងក្របខណ្ឌគោលនយោបាយរដ្ឋាភិបាលឌីជីថល បានដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអន្តរក្រសួង ដើម្បីពិនិត្យ និងពិភាក្សាទៅលើសេចក្តីព្រាងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ។

ស្របតាមស្មារតីនៃចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០ និងការចង្អុលបង្ហាញនៃយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាល ទី៤, **"ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥"** ដែលត្រូវបានគិតគូរប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងប្រាកដនិយមខ្ពស់ នឹងក្លាយជាផែនទីចង្អុលផ្លូវដ៏មានសារៈសំខាន់ក្នុងការធ្វើបរិវត្តកម្មឌីជីថល ។ ម្យ៉ាងទៀត ក្របខណ្ឌគោលនយោបាយនេះ ត្រូវបានរៀបចំឡើងដោយមានភាពឆ្លើយតបខ្ពស់ទៅនឹងនិន្នាការសកលនៃបដិវត្តន៍ឧស្សាហកម្ម ៤.០ ក៏ដូចជាបរិវត្តកម្មឌីជីថល ដែលបាននិងកំពុងធ្វើឱ្យនិម្មាបនកម្មសេដ្ឋកិច្ចពិភពលោក និងតំបន់ មានការវិវឌ្ឍឥតឈប់ឈរ ជាពិសេសក្នុងបរិការណ៍ដែលចាប់តាំងពីឆ្នាំ ២០២០ មក, បទពិសោធន៍ និងមេរៀននៃវិបត្តិជំងឺកូវីដ-១៩ បានបង្ហាញអំពីសក្តានុពលកាន់តែសំខាន់នៃបរិវត្តកម្មឌីជីថល ក្នុងការជំរុញការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ច ។

ក្របខណ្ឌគោលនយោបាយនេះ កំណត់នូវចក្ខុវិស័យក្នុងការ "កសាងសេដ្ឋកិច្ច និងសង្គមឌីជីថលរស់រវើក តាមរយៈការរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយក និងបរិវត្តកម្មឌីជីថល នៅក្នុងគ្រប់តួអង្គសង្គម ទាំងរដ្ឋ ទាំងប្រជាជន និង ទាំងធុរជន ដើម្បីជំរុញសម្ទុះកំណើនសេដ្ឋកិច្ចថ្មី និងលើកកម្ពស់សុខុមាលភាពសង្គម តាមគន្លងប្រក្រតីថ្មី" ដោយផ្តោតលើ អាទិភាព ៥ ធំៗ ក្នុងនោះរួមមាន៖

(១). ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល,

(២). ការកសាងទំនុកចិត្ត និងភាពជឿជាក់លើប្រព័ន្ធឌីជីថល,

(៣). ការកសាងពលរដ្ឋឌីជីថល,

(៤). ការកសាងរដ្ឋាភិបាលឌីជីថល និង

(៥). ការជំរុញធុរកិច្ចឌីជីថល ។

ជាលទ្ធផល អង្គប្រជុំបានវាយតម្លៃខ្ពស់ចំពោះក្រុមការងារអន្តរក្រសួង ដែលបានបំពេញការងារប្រកបដោយកិច្ចសហការ និងការទទួលខុសត្រូវខ្ពស់ក្នុងការរៀបចំចងក្រងសេចក្តីព្រាងក្របខណ្ឌគោលនយោបាយនេះឡើង ។ ជាមួយគ្នានេះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានអង្គប្រជុំ បានណែនាំដល់ក្រុមការងារធ្វើការកែសម្រួលឯកសារនេះតាមស្មារតី និងមតិយោបល់របស់អង្គប្រជុំ ដើម្បីនីតិវិធីអនុម័តឯកសារនេះក្នុងពេលឆាប់ៗខាងមុខ៕